


# សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង

## និយមន័យ

ក្នុងបរិបទព្រហ្មទណ្ឌ ជនណាដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះលើសំណុំរឿងរបស់ខ្លួនដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់។

សាលាជម្រះក្ដីគឺមានន័យថា "ស្ថាប័នមួយដែលបង្កើតឡើងដោយច្បាប់ ឯករាជ្យពីអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ឬមានឯករាជភាពខាងយុត្តាធិការលើរឿងក្ដីជាក់លាក់នានាក្នុងការសម្រេចសេចក្ដីលើបញ្ហាច្បាប់នៅក្នុងដំណើរការនៃរឿងក្ដី ដែលមានចរិកលក្ខណៈជាការវិនិច្ឆ័យ។"

សាលាជម្រះក្ដីត្រូវតែត្រូវបានបង្កើតឡើងដោយច្បាប់ និងបំពេញលក្ខខណ្ឌបីដូចខាងក្រោម ដើម្បីអាចកាត់ក្ដីសំណុំរឿងព្រហ្មទណ្ឌបាន៖

សាលាជម្រះក្ដីមានសមត្ថកិច្ច៖ សាលាជម្រះក្ដីមានសមត្ថកិច្ចគឺជាសាលាជម្រះក្ដី ដែលមានដែនយុត្តាធិការក្នុងការជម្រះក្ដី មានន័យថា សាលាជម្រះក្ដីបានទទួលសិទ្ធិអំណាចក្នុងការធ្វើសេចក្ដីសម្រេចទៅលើកម្មវត្ថុ ដែលបានកំណត់ដោយច្បាប់។ សាលាក្ដីនេះក៏ត្រូវមានបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍សមរម្យផងដែរ។

សាលាជម្រះក្ដីឯករាជ្យ៖ ដើម្បីធានាឯករាជភាពរបស់ស្ថាប័នតុលាការ ត្រូវតែការពារប្រឆាំងនឹងទំនាស់ផលប្រយោជន៍ ការគំរាមកំហែង និងពីការជ្រៀតជ្រែកផ្នែកនយោបាយ ដោយស្ថាប័ននីតិប្រតិបត្តិ ឬនីតិបញ្ញត្តិក្នុងដំណើរការនីតិវិធី និងសេចក្ដីសម្រេចចិត្តរបស់ខ្លួន។

សាលាជម្រះក្ដីមិនលម្អៀង៖ ចៅក្រមដាច់ខាតមិនត្រូវកាត់ក្ដីដោយលម្អៀង ឬបុរេវិនិច្ឆ័យជាមុនលើសេចក្ដីសម្រេចរបស់ខ្លួន ឬស្មានទុកជាមុនលើលទ្ធផលនៃសំណុំរឿងជាក់លាក់។ លើសពីនេះ សាលាជម្រះក្ដីត្រូវតែបង្ហាញពីភាពមិនលម្អៀងរបស់ខ្លួនដោយសមហេតុផលនៅចំពោះមុខអ្នកសង្កេតការណ៍។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងមានចែងនៅក្នុងមាត្រា ១០ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស "មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ។" ហើយសិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។



# ច្បាប់ជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងមានចែង នៅក្នុងមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ "អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិអំណាចតុលាការជាអំណាចឯករាជ្យ សេរីភាពរបស់ប្រជាពលរដ្ឋ [...]។" និង មានចែងនៅក្នុងបញ្ញត្តិជាច្រើន។




## សារសំខាន់

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង គឺជាសិទ្ធិស្នូលនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សិទ្ធិនេះធានានៃនីតិវិធីក្នុងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ និងនីតិរដ្ឋ។ លក្ខខណ្ឌតម្រូវនៃសាលាជម្រះក្ដីមានសមត្ថកិច្ច និងមិនលម្អៀងធានាថា មន្ត្រីតុលាការដែលជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌមានជំនាញផ្នែកច្បាប់ និងសុចរិតភាពគ្រប់គ្រាន់ ដើម្បីធ្វើសេចក្ដីសម្រេចដោយសត្យានុម័ត និងអព្យាក្រឹតផ្អែកទាំងស្រុងតែលើភស្តុតាង និងស្របតាមច្បាប់ពាក់ព័ន្ធតែប៉ុណ្ណោះ។

លក្ខខណ្ឌតម្រូវនៃសាលាជម្រះក្ដីឯករាជ្យបានធានាថា សេចក្ដីសម្រេចដែលចេញដោយតុលាការគឺមិនទទួលរងឥទ្ធិពលពីហេតុផលនយោបាយ ឬមូលហេតុផ្ទាល់ខ្លួន។ លក្ខខណ្ឌតម្រូវនេះគឺជាឫសគល់នៅក្នុងគោលការណ៍នៃការបែងចែកអំណាច ដោយគោលការណ៍នេះធានានូវតុល្យភាពអំណាចរវាងអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងអំណាចតុលាការ។ យន្តការនេះការពារកុំឱ្យមានអំណាចលើសលុបព្រមទាំងការពារមិនឱ្យមានការបំពានអំណាចគ្នាទៅវិញទៅមក ដូច្នេះទើបអាចធ្វើឱ្យនីតិរដ្ឋមានការរីកចម្រើន ដោយធានាថា ភាគីនៃដំណើរការនីតិវិធីត្រូវបានប្រព្រឹត្តដោយស្មើភាពគ្នា និងគ្មានការរើសអើង។

## ដែនកំណត់

សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង គឺជាសិទ្ធិដាច់ខាត ដែលមិនអាចលើកលែងបានទេ រួមទាំងនៅក្នុងស្ថានភាពអាសន្នផងដែរ។

លក្ខខណ្ឌតម្រូវនៃសាលាជម្រះក្ដីមានសមត្ថកិច្ច ឯករាជ្យភាព និងភាពមិនលម្អៀងអនុវត្តបន្ថែមទៀតចំពោះតុលាការទាំងអស់ ឱ្យស្របនឹងនិយមន័យសាលាជម្រះក្ដី មិនថាជាតុលាការសាមញ្ញ ឬឯកទេស តុលាការស៊ីវិល ឬយោធាឡើយ។

លក្ខខណ្ឌទាំងនេះក៏អនុវត្តចំពោះតុលាការសាសនា ឬតុលាការដោយផ្អែកលើច្បាប់ទំនៀមទម្លាប់ដែលទទួលស្គាល់ដោយរដ្ឋ និងប្រគល់កិច្ចការងារណាដែលពាក់ព័ន្ធនឹងតុលាការ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights
Sweden Sverige
People Change the World Diakonia

CC BY NC SA